DEPARTMENT OF
HEALTH CARE SERVICES

**SAN JOAQUIN COUNTY BEHAVIORAL HEALTH SERVICES**

**(សេវាសុខភាពអាកប្បកិរិយាខោនធីសាន់ចូឃ្វីន)**

1212 NORTH CALIFORNIA STREET STOCKTON, CA 95202

Tel: (209) 468-8700 Fax: (209) 468-2399

សេវាសុខភាពផ្លូវចិត្ត សេវាព្យាបាលញៀនថ្នាំ សេវាថែទាំ ឱសថស្ថានសុខភាពផ្លូវចិត្ត


ថ្ងៃទី 21 ខែ កក្កដា ឆ្នាំ 2008

# លិខិតស្នើសុំកែប្រែផែនការ ដើម្បីពន្យាពេល និងផ្តល់ថវិកាសំរាប់ឆ្នាំក្រោយ (2008-09) នៃ ផែនការបីឆ្នាំស្តីពីច្បាប់សេវាសុខភាពផ្លូវចិត្តបឋម

## ការណែនាំផ្សេងៗ :

ត្រូវបានណែនាំឱ្យ សេវាសុខភាពអាកប្បកិរិយា (Behavioral Health Services) [BHS] ស្នើការអនុម័តពីក្រសួងសុខាភិបាលផ្លូវចិត្ត (DMH) សុំកែប្រែផែនការ ដោយពន្យាពេលផែនការបីឆ្នាំរបស់ច្បាប់សេវាកម្មសុខភាពផ្លូវចិត្តបឋម (MHSA) សំរាប់ឆ្នាំក្រោយ (2008-09) និងកែប្រែថវិកា ដើម្បីបញ្ចូលទឹកប្រាក់សំរាប់ឆ្នាំទីបួន ដែលមានចំនួន $12,940,050 ។ បច្ចុប្បន្ន ថវិកាទាំងនេះពុំត្រូវបានរៀបចំ និងចំណាយឡើយ ហើយនឹងត្រូវប្រើប្រាស់ដើម្បីបន្តសេវាកម្ម និងកម្មវិធីទាំងអស់ដែលបានអនុម័តពីមុន ក្នុងផែនការបីឆ្នាំរបស់ MHSA ។

## មូលហេតុនៃការណែនាំ :

នៅថ្ងៃទី 1 ខែ តុលា ឆ្នាំ 2006 ក្រសួងសុខាភិបាលផ្លូវចិត្ត (DMH) បានអនុម័តលើផែនការបីឆ្នាំរបស់គម្រោងសមាសភាពសេវាកម្ម និងការគាំទ្រសហគមន៍ (Community Services and Supports Component) របស់ MHSA សំរាប់ខោនធីសាន់ចូឃ្វីន ដែលមានទឹកប្រាក់សរុបចំនួន $12,386,190 ។ បន្ថែមលើនេះ នៅថ្ងៃទី 7 ខែ កុម្ភៈ ឆ្នាំ 2008, DMH បានអនុម័តថវិកាបន្ថែមសំរាប់កម្មវិធី One-Time Technology ដែលមានទឹកប្រាក់ចំនួន $1,233.040 ។ ជាលទ្ធផល នៅថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2008, DMH បានអនុម័តលើការកែប្រែផែនការដែលបង្កើនថវិកាផែនការបីឆ្នាំរបស់ MHSA ចំនួន $918,613 សំរាប់ការពង្រីកភាពជាដៃគូសេវាកម្មពេលលេញសំរាប់ជនពេញវ័យ និងចំនួន $984,147 ដើម្បីចាប់ផ្តើម កម្មវិធីត្រៀមការប្រុងប្រយ័ត្នរបស់ខោនធី (County’s Prudent Reserve) ។

ឥឡូវនេះ DMH បានផ្តល់ជម្រើសឱ្យខោនធីទាំងឡាយ ពន្យាផែនការបីឆ្នាំរបស់ MHSA បឋមទៅឆ្នាំទីបួន ជាជាងអនុវត្តទៅតាមជម្រើសដើម ដើម្បីបង្កើតផែនការបីឆ្នាំលើកទីពីរ ។ ចំពោះឆ្នាំទីបួន បានស្នើសុំថវិកាចំនួន $12,940,050 និងរួមទាំងថវិកាចំនួន $7,515,936 ទៀតសំរាប់កម្មវិធីភាពជាដៃគូសេវាកម្មពេញលេញ ។ សំរាប់ព័ត៌មានបន្ថែម សូមមើលនៅទំព័រភ្ជាប់ A ដែលមានព័ត៌មានសង្ខេបអំពីថវិកា តាម ប្រភេទចំណាយនៃផែនការបីឆ្នាំ និងថវិកាស្នើសុំសំរាប់ការពន្យាទៅឆ្នាំទីបួន ។ ចំពោះទំព័រភ្ជាប់ B វិញរួមមាន ឯកសារស្តីពីបទបង្ហាញរបស់បុគ្គលិកជូនគណៈក្រុមប្រឹក្សាសុខភាពផ្លូវចិត្តខោនធីសាន់ចូឃ្វីន ដែលពន្យល់អំពីការកែប្រែផែនការដែលបានស្នើសុំ និងផ្តល់ព័ត៌មានស្តីអំពីសាវតាមួយចំនួន ។

ចំពោះការណែនាំឱ្យស្វះស្វែងរកការអនុម័តពី DMH សំរាប់ការកែប្រែផែនការ ដើម្បីបន្តសេវាកម្ម និងកម្មវិធីសំរាប់ឆ្នាំ 2008-09 ត្រូវបានពិនិត្យឡើងវិញជាមួយគណៈក្រុមប្រឹក្សាសុខភាពផ្លូវចិត្តខោនធីសាន់ចូឃ្វីន នៅថ្ងៃទី 16 ខែ កក្កដា ឆ្នាំ 2008 ហើយនឹងត្រូវបានពិនិត្យឡើងវិញជាមួយនឹងគណៈកម្មការដឹកនាំអ្នកពាក់ព័ន្ធរៀបចំផែនការរបស់ MHSA នៅថ្ងៃទី 12 ខែ សីហា ឆ្នាំ 2008 ។ បន្ទាប់ពីនេះ ការកែប្រែផែនការដែលទទួលបានការណែនាំនេះ នឹងត្រូវយកទៅប្រគល់ជូនគណៈគ្រប់គ្រង ដើម្បីសុំការអនុម័ត ដោយភ្ជាប់ជាមួយពង្រាងរបៀបវារៈជួបប្រជុំ នៅថ្ងៃទី 19 ឬ 26 ខែ សីហា ឆ្នាំ 2008 ។

ការបកប្រែឯកសារភ្ជាប់ទាំងពីរ នឹងអាចទទួលបានជាភាសាអេស្ប៉ាញ និងខ្មែរ អាស្រ័យតាមការស្នើសុំ ។

## ផលប៉ះពាល់លើផ្នែកហិរញ្ញវត្ថុ :

ប្រសិនការកែប្រែផែនការ ព្រមទាំងការផ្តល់ថវិកាដែលពាក់ព័ន្ធ មិនត្រូវបានអនុម័ត និងបន្ថែមទេនោះ ពេលនោះការផ្តល់ថវិកាសំរាប់សេវាកម្ម និងកម្មវិធីនានាដែលបានយល់ព្រមកាលពីពេលមុននៅក្នុងផែនការបីឆ្នាំ CSS របស់ MHSA នឹងត្រូវបានបញ្ចប់ ។

## វិធានការណ៍តាមដានដែលត្រូវចាត់ឡើង :

សូមស្វាគមន៏រាល់មតិយោបល់ទាំងឡាយ និងសូមផ្ញើតាមរយៈអ៊ីម៉ែល: mhsacomments@sjcbhs.org ។ ការផ្តល់យោបល់លើក្រដាស អាចផ្ញើតាមប្រៃសណីយ៏ទៅកាន់អាសយដ្ឋាន : Behavioral Health Services 1212 N. California St., Stockton, CA. 95202, attention:  Becky Gould ។ បន្ទាប់ពីការឆ្លើយតបរយៈពេល 30 ថ្ងៃជាសាធារណៈ និងត្រូវបានបញ្ចប់ និងដាក់ជនរួចរាល់ លិខិតស្នើស្នើសុំការកែប្រែផែនការ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត នឹងត្រូវផ្ញើជូន DMH សម្រាប់ពិនិត្យ និងអនុម័ត ។